## SPANDAN (ការញ័រ )

**Gandhiji** បានយកគំនិតពី **Gram Swaraj** ដើម្បីធ្វើអោយសម្រេចនូវគោលដៅរបស់វិទ្យាស្ថានប្រជាធិបតេយ្យ ។

- តាមរបាយការណ៍របស់គណៈកម្មការBalvant Rai នៅក្នុងឆ្នាំ១៩៥៧ គឺជាឆ្នាំដែលបានស្នើរសុំឆ្ពោះទៅ រកការបង្កើតអោយមានដំណើរការរបស់ក្រុមប្រឹក្សាឃុំ (the Gram Panchayats operational) ។
- នៅឆ្នាំ១៩៨៩ គឺជាឆ្នាំដំបូងបំផុតនៅ Lok Sabha ក៏ដូចជានៅ Raja Sabha ដែលសេចក្តីព្រាងច្បាប់ （the Panchayati Raj Bill) ត្រូវបានគេបង្ហាញ និងបានទទួលជោគជ័យយ៉ាងសម្បើម ។
- នៅឆ្នាំ១៩៩២ តាមរយៈការធ្វើវិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញលើកទី៧៣ សិទ្ធិក្នុងការបង្កើត Panchayts ត្រូវប្រកាសអោយប្រើ ។
- នៅក្នុងឆ្នាំ១៩៩៤ ច្បាប់នេះត្រូវគេបានយកមកអនុវត្ត តាមរយៈរដ្ឋាភិបាលរបស់លោក Uttar Pradesh ។

**Ashok Bhai:(នាយក PRA)**
**Sahabhagi Sikshan Kendra**

នៅក្នុងឆ្នាំ ១៩៩២ គឺជាឆ្នាំដែលច្បាប់ដ៏សំខាន់មួយត្រូវបានអនុវត្តក្នុងប្រទេសរបស់យើង ។ដែលច្បាប់នេះ គឺជាច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី ៧៣ ដែលផ្តោតជាសំខាន់ទៅលើការពង្រឹងអង្គការក្នុងស្រុកនិងធ្វើឱ្យការងាររបស់ពួកគេប្រកបទៅដោយប្រសិទ្ធិភាព ។

ចំពោះគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំ វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី ៧៣ នេះគឺជាការផ្លាស់ប្តូរដ៏សំខាន់មួយ ។ ច្បាប់នេះបានចែងនូវមាត្រាជាច្រើន ប៉ុន្តែ មានមាត្រាមួយដែលខ្ញុំគិតថាវាចាំបាច់បំផុតនោះគឺ ការផ្តល់ឱ្យក្រុមប្រឹក្សាឃុំរៀបចំបង្កើតផែនការអភិវឌ្ឍន៍ឃុំដោយខ្លួនឯង ។ ផែនការនេះសំដៅទៅលើការធ្វើផែនការខ្នាតតូច **(Micro-planning)** ដែលក្រុមប្រឹក្សាឃុំត្រូវវាយតំលៃពីធនធានដែលអាចយកមកប្រើប្រាស់ និងរៀបចំជាផែនការបាន （តើមានធនធានប៉ុន្មានដែលគួរឱ្យកត់សំគាល់នៅក្នុងភូមិ）។ ក្រុមប្រឹក្សាឃុំត្រូវផ្តោតសំខាន់ទៅលើការបំពេញឱ្យបានសេចក្តីត្រូវការផ្សេងៗរបស់សហគមន៍ដែលអ្នកភូមិរស់នៅ និងត្រូវធ្វើផែនការអភិវឌ្ឍន៍ឃុំដោយផ្អែកទៅលើតម្រូវការមូលដ្ឋាន ។ វិធីសាស្រ្តនេះនឹងជំរុញឱ្យមានការចូលរួមរបស់ប្រជាជនកាន់តែច្រើន

និងអាចដោះស្រាយនូវសេចក្តីត្រូវការរបស់ពួកគេ។ ដូច្នេះនៅពេលក្រុមប្រឹក្សាឃុំបង្កើតនូវផែនការអភិវឌ្ឍន៍ ភូមិ អនុវត្តផែនការទាំងនេះ និងវាយតំលៃពីផែនការនេះ។ តាមរយះវិធីសាស្ត្រនេះ នាំឱ្យផ្លាស់ប្តូរតាមរយះការខិតខំប្រឹងប្រែងរបស់ពួកគេផ្ទាល់។

**អត្ថាធិប្បាយ**

ដើម្បីឱ្យក្រុមប្រឹក្សាមានសមត្ថភាពអាចធ្វើដោយខ្លួនឯងបាន ដំណើរនៃការធ្វើការផែនការខ្នាតតូច ឬ ការធ្វើផែនការដោយមានការចូលរួមរបស់ក្រុមប្រឹក្សាឃុំ ដែលជាការខិតខំប្រឹងប្រែងមួយប្រកបដោយចេរភាព។ ក្នុងដំណើរការនេះ ការប្រមូលពតិមានជាច្រើនអំពីក្រុមប្រឹក្សាឃុំ គឺត្រូវធ្វើតាមរយះការចូលរួមរបស់ប្រជាជនក្នុងតំបន់។ បច្ចេកទេស **PRA** ត្រូវបានគេប្រើប្រាស់សំរាប់ប្រមូលពតិមានទាំងអស់នេះ។ **PRA** ជាវិធីសាស្ត្រដែលត្រូវអនុវត្តមួយ ជំហានម្តងៗ តាមរយះវិធីសាស្ត្រនេះ ជំរុញឱ្យមានការចូលរួមពីប្រជាជនកាន់ច្រើន។

**សេចក្តីណែនាំ**

**អត្ថាធិប្បាយ**

មុននឹងចាប់ផ្តើមនៃសេចក្តីណែនាំ យើងត្រូវដឹងថា :

- តើនៅកន្លែងណាដែលសមាជិកក្រុម និងអ្នកស្រុកត្រូវបានពន្យល់ថាអ្វីទៅជា **micro planning** នោះ?

- ហេតុអ្វីបានជា **micro planning** មានភាពចាំបាច់ និងតើក្រុមប្រឹក្សាឃុំ **(GramPanchayats)** និងធ្វើផែនការនេះ ដោយរបៀបណា?

- មានបញ្ហាជាច្រើន ដែលកើតឡើងនៅពេលដែលអ្នកព្យាយាមឱ្យមានការពិភាក្សាកាន់តែស៊ីជំរៅនោះ សំនួរដែរលេចឡើងនៅក្នុងអារម្មណ៏របស់សមាជិកក្រុម និងសម្រេចឡើងក្នុងអំឡុងពេលពិភាក្សាគ្នានោះជាក់ជាមិនខាន។

**កិច្ចសន្យាល្អិតល្អន់ (Intensive Contract)**

សកម្មភាពដំបូងនៃការអនុវត្តវិធីសាស្ត្រ **PRA** គឺត្រូវប្រាកដថាជានិច្ចកាលតែងតែជាកិច្ចការដែលជាប់ទាក់ទងជាមួយអ្នកស្រុកដូចជា ការប្រជុំជាមួយពួកគាត់ ការប្រាប់ពួកគេអំពីកម្មវិធី ការជំរុញ និងការអញ្ជើញពួកគេចូលក្នុងសកម្មភាពផ្សេងៗ ដែលទាំងអស់នេះហើយដែលជាកាតព្វកិច្ចដំបូងបំផុតដែលត្រូវធ្វើក្នុងវិធីសាស្ត្រនេះ។

**ក្មេងស្រី និង មីងម្នាក់**

**ក្មេងស្រី :** ជំរាបសួរមីង

មីងនៅចាំខ្ញុំបានទេ? ខ្ញុំគឺ **Arehana** ខ្ញុំធ្វើការជាមួយអង្គការដែលធ្វើការសំរាប់ **The Panchayati Raj** ដែលអង្គការខ្ញុំផ្តល់ការបណ្តុះបណ្តាលដល់ **The Pradhan and The Panches** ។

ថ្ងៃនេះ ពួកខ្ញុំមកទីនេះដើម្បីរៀបចំផែនការមួយចំនួនសំរាប់ **The Panchayats** ។ ហើយពួកយើងត្រូវការព័តិមានមួយចំនួនដើម្បីធ្វើឱ្យសំរេចនូវផែនការនេះ ។

**-អត្ថាធិប្បាយ**

ក្នុងការធ្វើទំនាក់ទំនងជាមួយអ្នកភូមិត្រូវប្រកាន់ភ្ជាប់នូវភាពទន់ភ្លន់ និងសាមញ្ញ

**ក្មេងស្រី :** យើងចង់ធ្វើការសិក្សាពីបញ្ហាមួយចំនួនក្នុងភូមិរបស់អ្នក ហើយចង់ឱ្យមនុស្សទាំងអស់គ្នា ទាំងប្រុសទាំងស្រីចូលរួមប្រជុំ ដូច្នេះខ្ញុំសុំអញ្ជើញអ្នក ដើម្បីចូលក្នុងការប្រជុំនោះ តើអ្នកមីងយល់យ៉ាងម្តេចបើខ្ញុំអញ្ជើញអ្នកមីងទៅឥឡូវនេះ ?

**ការធ្វើផែនទីភូមិ (Social Mapping)**

<u>សមាជិកក្រុមឡើងបង្ហាញដល់អ្នកភូមិ</u>

ថ្ងៃនេះពួកយើង និងគូផែនទីនូវចំនុចសំខាន់ក្នុងភូមិរបស់លោកអ្នក ហើយតាមរយៈផែនទី យើងព្យាយាមស្វែងរកនូវចំនួនផ្ទះដែលស្ថិតនៅក្នុងភូមិ ។ ជាងនេះទៅទៀត យើងចង់ដឹង កន្លែងណាដែលមានផ្លូវក្រាលថ្ម និងមានផ្លូវលំមួយចំនួននៅក្នុងភូមិ ។ ដែលអ្វីទាំងអស់នេះត្រូវបានបង្ហាញ នៅលើដី និងតាមរយៈផែនទីនេះ ដែលបានសង្កេតនូវចំនួនវត្ថុជាច្រើន ដូចជា ចំនួនសរុបរបស់ផ្ទះអ្នកភូមិ ។ តើអ្នកទាំងអស់គ្នា ស្គាល់ទីតាំងផ្ទះរបស់អ្នករឺទេ? យើងនឹងគូផែនទីភូមិនេះ ហើយតាមរយៈផែនទីនេះ យើងនឹងពណ៌នាពីផ្ទះដែលអ្នកភូមិនៅ ផ្លូវ សាលា មជ្ឈមណ្ឌលសុខភាពកុមារ ។ ទាំងអស់នេះ នឹងត្រូវគូនៅក្នុងភូមិរបស់អ្នកភូមិ?

**ការអត្ថាធិប្បាយ**

-សកម្មភាពនេះវាបង្ហាញពីស្ថានភាព លក្ខខ័ណ្ឌរស់នៅរបស់អ្នកភូមិ ។ ផែនទីនេះគូសឡើងដើម្បីយល់ដឹងពីស្ថានភាពដែលអ្នកភូមិរស់នៅក្នុងជីវិតរបស់គេ ។ ជាងនេះទៅទៀតវាជួយឱ្យយើងទទួលបានពតិមានជាមូលដ្ឋានលើទិដ្ឋភាពបច្ចុប្បន្នរបស់អ្នកភូមិដូចជា ការចាត់ថ្នាក់ផ្ទះ ធនធានដែលអាចរកបានសំរាប់គ្រួសារ និងហេដ្ឋារចនាសម្ព័ន្ធភូមិដូចជា ផ្លូវ អណ្តូងស្នប់ សាលារៀន ដែលវាអាចត្រូវបានបង្ហាញនៅក្នុងភូមិ ។

**ក្មេងស្រីធ្វើការទំនាក់ទំនងជាមួយអ្នកភូមិ?**

ផ្ទះនេះជាផ្ទះរបស់អ្នកណាគេ? នរណាជាម្ចាស់ផ្ទះនេះ?

**-Munilal**

តើគាត់ស្ថិតនៅក្នុងវណ្ណៈណា?

-**Raidas**

តើនរណារស់នៅផ្ទះ បន្ទប់នោះ?

-**Muruli**

តើគាត់ធ្វើអ្វីដែរ?

-**Passi**

មានបញ្ហាមួយដែលកើតឡើងគឺ ទឹកសំរាប់ហូប

-លើសពីនេះទៅទៀត តើមានផ្សេងទៀតទេ ដែលកើតឡើងនៅទីនោះ?

-ផ្លូវទីពីរ វាមិនទាន់ចាក់កៅស៊ូ និងមិនមានថ្មនៅឡើយទេដែលពេលភ្លៀង ផ្លូវនេះ វាពោលពេញទៅដោយភក់។ ហើយនៅពេលអ្នកភូមិ ដើរកាត់ផ្លូវនេះនៅរដូវភ្លៀង ពួកគេត្រូវឆ្លងកាត់។

**ផែនទីធនធានរបស់ភូមិ**

<u>សមាជិកក្រុមកំនត់នូវចំនួនប្រជាជនក្នុងភូមិ :</u>

នៅក្នុងភូមិនីមួយៗ ប្រភពធនធានជាច្រើនអាចយកទៅប្រើប្រាស់បាន។

តើអ្នកយល់ច្បាស់ទេអំពីអត្ថន័យពាក្យថា ធនធាន?

តើអ្នកអាចផ្តល់ឱកាស ដើម្បីប្រាប់ និងបង្ហាញពួកយើងអំពីប្រភពធនធានផ្សេងៗដែលអាចយកមកប្រើប្រាស់បាននៅក្នុងភូមិបានដែរឺទេ? ឧទាហរណ៍ ធនធានទាំងនោះមានដូចជា ដីស្រែ ដីចំការ និងបឹងផ្សេងៗ។ តើអ្នកអាចប្រាប់ខ្ញុំបានទេអំពីប្រភពធនធានផ្សេងៗដែលអាចស្វែងរកបាននៅក្រៅភូមិរបស់អ្នក?

**ការអត្ថាធិប្បាយ**

នៅក្នុងភូមិមានធនធានជាច្រើនប្រភេទ។

**សមាជិកក្រុមជាមួយប្រជាជនម្នាក់នៅក្នុងភូមិ :**

តើអ្នកកំពុងធ្វើអ្វី?

នេះគឺជាភូមិមួយ

នៅខាងលើនេះជាចំនួនប្រជាជនទាំងអស់។

ប្រាកដណាស់

**ការអត្ថាធិប្បាយ**

ក្រោយពីបានគូផែនទីធនធាន ធនធានជាច្រើនដូចជា វាលស្រែ សួនដំណាំ ព្រៃឈើ បឹងបួរផ្សេងៗត្រូវបង្ហាញតាមរយៈគំនូសសញ្ញា។ ជាមួយនឹងផែនទីធនធាន ធនធានជាច្រើនដែលអាចប្រើប្រាស់បានក្នុងភូមិ ត្រូវបាន

លើកយកមកបង្ហាញ ដែលធនធានទាំងអស់នេះមានសារះសំខាន់ក្នុងការបង្កើតផែនការអភិវឌ្ឍន៍ភូមិ។ តាមរយៈធនធានដែលមានស្រាប់ ទាំងអស់នេះដែលគេអាចយកប្រើប្រាស់បានកំនត់ឱ្យឃើញ។

អ្នកភូមិជាអ្នកបង្កើត និងបង្ហាញនូវធនធានដែលអាចយកមកប្រើប្រាស់បាននៅក្នុងភូមិ តាមរយៈការប្រើប្រាស់បច្ចេកទេសពិសេស និងមានការការទាក់ទាញ (**unique and attractive techniques**)។ ធនធានទាំងអស់នេះ ត្រូវបានបង្ហាញតាមរយ : ពណ៌ សូចនករ និងនិមិត្តសញ្ញាផ្សេងៗ។ នៅពេលផែនទីនេះត្រូវបានគូរចរាល់ហើយនោះ បន្ទាប់មកត្រូវចំលងវា ចូលទៅក្នុងផ្ទាំងក្រដាស **(Card Sheet)** ជាមួយការជួយជ្រោមជ្រែងពីអ្នកភូមិ។

## ការវិភាគការចិញ្ចឹមជីវិត

### សមាជិកក្រុមធ្វើការកំណត់ប្រជាជនក្នុងភូមិ :

ក្នុងគោលបំណងអភិវឌ្ឍន៍នូវគំរោងផែនការរបស់ភូមិ ជាដំបូងយើងត្រូវយល់អំពីលក្ខខ័ណ្ឌសេដ្ឋកិច្ចក្នុងភូមិ។ សំរាប់ហេតុផលនេះ យើងនឹងមានការពិភាក្សាទៅលើរបៀបចិញ្ចឹមជីវិតរបស់ប្រជាជននៅក្នុងភូមិ។ ការពិភាក្សា សង្កត់ធ្ងន់ទៅលើមុខរបរដែលប្រជាជនប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនក្នុងភូមិ និងរបៀបចិញ្ចឹមជីវិតប្រចាំថ្ងៃ។ ពួកយើងនឹងធ្វើការពិភាក្សាទៅលើព័តិមានមូលដ្ឋានមួយចំនួននៅក្នុងភូមិ។ ជាងនេះទៅទៀត សូមប្រាប់ខ្ញុំអំពីឈ្មោះភូមិនេះ?

- **Bhagul**

### អត្ថាធិប្បាយ:

លំហាត់នេះ គឺត្រូវបានអនុវត្តដើម្បីឱ្យបានយល់អំពីលក្ខខ័ណ្ឌសង្គម និង សេដ្ឋកិច្ចនៃប្រជាជនក្នុងភូមិ។

<u>សមាជិកក្នុងក្រុម និងប្រជាជនក្នុងភូមិ</u>

តើមានចំនួនប្រជាជនប៉ុន្មាននាក់ រស់នៅជាប់លាប់ក្នុងភូមិនេះ?

- ១៥៤

១៥៤ ជាចំនួនប្រជាជន រឺ ជាចំនួនគ្រួសារ?

- ១៥៤ គ្រួសារ

ជាភាពប្រាកដប្រជា តើក្នុងគ្រួសារនីមួយៗមានសមាជិកប៉ុន្មាននាក់? តើចំនួនប្រជាជនសរុបចំនួនប៉ុន្មាន?

បុរស : ប្រហែល **15,000**

ស្រី : តើមានវណ្ណៈផ្សេងអ្វីខ្លះនៅក្នុងភូមិ?

បុរស : នៅក្នុងភូមិ **Bhagul** អ្នកភូមិស្ថិតក្នុងវណ្ណៈផ្សេងៗចំនួន ១១ប្រភេទ។

ស្ត្រី : តើនៅទីនេះ ជាវណ្ណៈអ្វី?

បុរស : មានវណ្ណៈ **Brahman, Kshtriya, Dhanuk, Dhobi, Passi, Chamar, Bania, Muslim, Barayee, Bhurjee, Gadhariya** ។

**អត្ថាធិប្បាយ**

តាមរយៈវិធីសាស្ត្រនេះ ការពិភាក្សានិង អន្តរកម្មត្រូវបានអនុវត្តឡើងជាមួយអ្នកភូមិ។

សមាជិកក្រុម និង បុរស :

តើប្រជាជននៅទីនេះពួកគាត់ធ្វើការងារអ្វី?

បុរស :ប្រជាជននៅទីនេះពួកគាត់ជាកសិករ កម្មករអគ្គីសនី អ្នកកាត់ដេរ និងជាអ្នកលក់ដូរ។

**អត្ថាធិប្បាយ**

ក្រោយពីព័ត៌ត្រូវបានប្រមូលរួចរាល់ វាត្រូវបានបង្ហាញជាលក្ខណៈសាមញ្ញ តាមរយៈ **Charts, pie- diagram or histogram** ។

សមាជិកក្រុមធ្វើការជាមួយអ្នកភូមិ

ចំពោះគ្រឿងប្រើប្រាស់ក្នុងផ្ទះបាយ អ្នកចង់បានន័យថាវាផលិតឡើងដីដ្ឋ?

-ដីដ្ឋ

នៅក្នុងវិស័យកសិកម្ម តើអ្នករកចំនូលបានប៉ុន្មាន?

-សំរាប់ ១ **Bigha** យើងទទួលបាន **Rs 1000**

តើមានប្រជាជនប៉ុន្មាននាក់ទៅនៅ **Rajgiri?**

-មាន ៤ គ្រួសារ។

ក្មេងស្រីៈតើមានគ្រួសារប៉ុន្មាន ដែលធ្វើការងារប្រើប្រាស់ឬស្សី **(bamboo work)** ។

បុរស់ចំណាស់ : ៦គ្រួសារ

**អត្ថាធិប្បាយ**

ការចិញ្ចឹមជីវិតវាតែងតែផ្សារភ្ជាប់ជាមួយនិងចំនូលដែលវាជាបញ្ហាក្តៅកកក់? នៅពេលប្រមូលព័ត៌មានពីវិធីសាស្ត្រនេះ អ្នកត្រូវប្រាកដថាអ្នកបានទទួលព័ត៌មានពិតប្រាកដពីអ្នកភូមិ។

**ការវិភាគអំពីអាកាសធាតុ**

សមាជិកក្រុមធ្វើការជាមួយអ្នកភូមិ

សូមស្វាគមន៍អ្នកទាំងអស់គ្នា

ដូចដែលយើងបានរៀបរាប់រួចមកហើយ វាមានផែនការជាច្រើនដែលអាចធ្វើសំរាប់អ្នកភូមិ។ សំរាប់ហេតុផលនេះ យើងត្រូវការព័ត៌មានជាច្រើន ពីអ្នកទាំងអស់គ្នា **PRA** ជាផែនការមួយដែលយើងយកមកប្រើ។

**អត្ថាធិប្បាយ**

ការវិភាគពីអាកាសធាតុនេះ គឺជាមូលដ្ឋានដើម្បីស្គាល់ និងយល់ពីការផ្លាស់ប្តូរ ដែលមនុស្សនៅក្នុងភូមិធ្លាប់បានធ្វើដូចជា ការផ្លាស់ប្តូរដោយលក្ខខ័ណ្ឌអាកាសធាតុ។

សមាជិកក្រុម និងស្ត្រីម្នាក់

តើជំងឺប្រភេទណាដែលអ្នកស្រីមានការព្រួយបារម្ភចំពោះអ្នកភូមិ?

- ជមងឺរាគមូល ក្អួតចង្អោរ បញ្ហាដែលទាក់ទងនឹងភ្នែក។

**អត្ថាធិប្បាយ**

វាជាការសំខាន់ណាស់ក្នុងការស្គាល់នូវវិបត្តិដែលអ្នកភូមិកំពុងជួបប្រទះនៅក្នុងកំឡុងពេលការប្រែប្រួលអាកាសធាតុ ដើម្បីនឹងស្គាល់ពីបុព្វហេតុនៃបញ្ហា និងការស្វែងរកដំណោះស្រាយដ៏សមរម្យសំរាប់វិបត្តិ។ ការប្រមូលពត៌មានផ្សេងៗដែលទាក់ទង និងអាកាសធាតុគឺជាកត្តាចំបងសំរាប់ការធ្វើផែនការអភិវឌ្ឍន៍ភូមិ។

សមាជិកក្រុមការងារ និងស្ត្រី

តើជាទូទៅ អ្នកស្រីចំណាយលុយប៉ុន្មានក្នុងការពិនិត្យសុខភាពជាមួយគ្រូពេទ្យ?

ស្ត្រី : ប្រហែលជា **Rs 250-300**

ក្រុមការងារ : តើពេលណាដែលអ្នកទៅពិនិត្យសុខភាពក្នុងមន្ទីពេទ្យរដ្ឋ? តើវាមានបញ្ហាអ្វីខ្លះ កើតឡើងពេលដែលអ្នកទៅ?

ស្ត្រី : គ្រូពេទ្យរបស់រដ្ឋ ប្រាប់យើងថា ថ្នាំពេទ្យដែលយើងរកនោះ មិនមានទេ គឺត្រូវទៅទិញវាពីខាងក្រៅភូមិ។

ក្រុមការងារ : កំឡុងពេលមានជំងឺ តើអ្នកស្រីចំណាយលុយអស់ប៉ុន្មានដើម្បីព្យាបាលជំងឺ? ឧបមាថាប្រសិនបើអ្នកស្រីរកប្រាក់បាន **Rs 100** តើអ្នកត្រូវចំណាយលុយប៉ុន្មាន ដើម្បីចំណាយសម្រាប់ការព្យាបាលនោះបាន ជាសះស្បើយ?

ស្ត្រី : ពេលដែលមាននរណាម្នាក់ឈឺ យើងត្រូវចំណាយលុយពី **500** ទៅ **600 rupees**។ នៅពេលមានជំងឺធ្ងន់យើងត្រូវចំណាយលុយចន្លោះពី **Rs 800** ទៅ **900** និងពេលដែលយើងឈឺធ្ងន់ គឺយើងត្រូវទៅខ្ចីលុយគេ។

CHAPATTI (Indian bread which is circular diagra) (នំប៉័ងឥណ្ឌាមានរាងមូល)

ក្រុមការងារបង្ហាញទៅអ្នកភូមិ :

ពេលដែលត្រូវការការជួយគាំទ្រផ្សេងៗ តើមានអង្គការ រឺកន្លែងណាខ្លះដែលអ្នកចង់ព្យាបាល ។ អ្នកប្រហែលជាមានអារម្មណ៏ផ្សារភ្ជាប់ទៅអង្គការដូចមន្ទីពេទ្យ **Aganwadi kendra** : ពេលដែលអ្នកនៅទីនោះ អ្នកនឹងទទួលបានផលប្រយោជន៏ពីវា ។ អ្នកប្រហែលជាស្វែងរកគ្រូពេទ្យរបស់អ្នក ។

តើនរណាជាមនុស្សនោះ រឺ អង្គការណាមួយ ដែលអ្នកនឹងទៅរកនោះ?

## អត្ថាធិប្បាយ

តាមរយៈការធ្វើនេះ យើងអាចប្រមូលពតិមានអំពីមនុស្ស រឺ អង្គការទាំងនោះ ដែលអ្នកភូមិគិតថា គួរទុកចិត្ត និងមានទំនាក់ទំនងល្អជាមួយពួកគេ ។ សកម្មភាពនេះ អ្នកអាចធ្វើលើក្រដាស ដែលកាត់ជារង្វង់មូល (ដែលទំរង់នេះដូចជា **chapatti**) ដូច្នេះវាត្រូវបានគេហៅថា **chapatti Diagram** ។

## ចំណាត់ថ្នាក់ម៉ាទ្រិក ឬក្រលាចក្រត្រង្គ (Matrix Ranking)

សមាជិកក្រុមនិងអ្នកភូមិ

អ្នកទាំងអស់គ្នាបានចូលរួមជាមួយនឹងសកម្មភាពជាច្រើនដូចជា **chapatti diagram** ការធ្វើផែនទីភូមិ ការវិភាគពីការចិញ្ចឹមជីវិត និងអាកាសធាតុជាដើម ។ ឥឡូវនេះយើងចាប់ផ្តើម ធ្វើការចាត់ថ្នាក់ **Matrix** ដែលជួយពួកយើងឱ្យស្គាល់ពីអ្វីដែលជាអាទិភាពរបស់លោកអ្នក? ។

តើវត្ថុណាខ្លះដែលអ្នកទាំងអស់គ្នាចាប់អារម្មណ៏ ?

យើងបានដឹងថានៅក្នុងភូមិរបស់អ្នកមានដំាដើមអំពៅប្រភេទខុសៗគ្នា ដែលអ្នកខ្លះបានបង្ហាញឈ្មោះខុសគ្នា ដូចជា ៨៨ និង ១២០ យឺត រឺឆាប់ ។ល ។ យើងចង់បានព័តិមានខ្លះ អំពីចំនុចខុសគ្នានេះ ។ អ្នកប្រាកដជាផ្តល់នូវគំនិតជាច្រើនខណៈពេលធ្វើកសិកម្មអំពៅ ។

តើដើមអំពៅនោះ វាខុសគ្នាត្រង់ណា?

## អត្ថាធិប្បាយ

នេះគឺជាបច្ចេកទេសចំរុះ **multi-dimensional technique**

សមាជិកក្រុមជាមួយកសិករនៅក្នុងភូមិ

- តើអំពៅប្រភេទ **Early and Samanira** មានចំនុចពិសេសៗខុសគ្នាយ៉ាងដូចម្តេច?

ដើមអំពៅប្រភេទ **Early** គឺប្រភេទដើមអំពៅដែលមានសុខភាពល្អ និងលូតលាស់បានល្អ ចំនែកឯងអំពៅប្រភេទ **Samanya** គឺអាចរកបាននៅក្នុងរោងចក្រស្ករស ដែលអត្រាក្នុងមួយ **quintal** នៃអំពៅប្រភេទ **Early**

breed វាមានតំលៃ **5 rupees** លើសអំពៅប្រភេទ **Samanya** ។

**អត្ថាធិប្បាយ**

ព័ត៌មានដែលទាក់ទងជាមួយនឹងប្រភេទរុក្ខជាតិ និងដើមឈើ គុណភាពនៃដី បច្ចេកទេសប្រមូលផលដោយប្រើប្រាស់ទឹកតិច ។ល។ ដែលព័ត៌មានទាំងអស់នេះ ត្រូវបានប្រមូលបានពីអ្នកស្រុក។ ប្រភេទនៃបច្ចេកទេសព័ត៌មាននេះ ត្រូវបានប្រមូលដោយធ្វើការគិតពិចារណា និងការណែនាំ អាទិភាព និងការវាយតំលៃរបស់អ្នកភូមិ។ ដែលអ្នកយកពត៌មាននេះផ្នែកមួយដ៏សំខាន់ក្នុងដំណើរការធ្វើផែនការ ។

**ការវិភាគទិន្នន័យ (Data Analysis)**

**អត្ថាធិប្បាយ**

នៅពេលដែលយើងអនុវត្តន៍វិធីសាស្ត្រ **PRA** នៅ **Gram Panchayats** បានបញ្ចប់ យើងនឹងប្រមូលបាននូវព័ត៌មានជាច្រើន។

**ការបង្ហាញរបស់សមាជិកក្រុមៈ**

តាមរយៈការអនុវត្តវិធីសាស្ត្រនេះ វាបានធ្វើឱ្យមានការយល់ដឹងកាន់តែប្រសើរទៅ ទិដ្ឋភាពពិតប្រាកដ និងកត់ត្រានូវព័ត៌មាន និងទិន្នន័យនានា។ វាមានសារៈសំខាន់ណាស់ក្នុងការដឹងអំពីរបៀបដែលទិន្នន័យត្រូវបានបង្ហាញទៅដល់ប្រជាជនក្នុងភូមិ។ តាមរយៈវិធីសាស្ត្រនេះ ប្រជាជនក្នុងភូមិត្រូវទទួលដឹងពីអ្វីដែលក្រុមការងារកំពុងធ្វើ និងពីព័ត៌មានដែលយើងត្រូវការប្រមូលពីពួកគាត់? រាល់ពត៌មានត្រូវតែសរសេរដាក់នៅក្នុងក្រដាសផ្ទាំងធំមួយ។

**អត្ថាធិប្បាយ**

កាបង្ហាញដោយភាពទាក់ទាញ និងគួរឱ្យចាប់អារម្មណ៍អំពីពត៌មានដែលប្រមូលបាន គឺជាសិល្បៈ និងវិធីសាស្ត្រមួយដ៏សំខាន់។

**ប្រតិកម្មរវាងក្រុមការងារ :**

ស្ត្រី : មាន ១៥៤គ្រួសារ និង ផ្ទះចំនួន ១០៨

ស្ត្រីទី២ : ក្នុងភូមិមានអណ្តូងទឹកផងដែរ ដែលសរុប មានចំនួន ៧ អណ្តូង។

សមាជិកសំរបសំរួល : តើអ្នកដឹងទេ ថាមានចំនួនប្រជាជនប៉ុន្មាននាក់ក្នុងភូមិ ?

## ការបង្ហាញ

ពួកយើងជួបគ្នាម្តងទៀតហើយ ហើយពេលនេះក្រុមការងារយើងបង្ហាញអំពី គំរោងមួយចំនួននៅទីនេះ។

**អត្ថាធិប្បាយ**

នៅក្នុងភូមិ ដោយមានការចូលរួមពីប្រជាជនពីក្រុមនីមួយៗ ព័ត៌មានទាំងអស់ត្រូវបានរក្សាទុកចំពោះមុខក្រុមដែលបានជ្រើសរើសមក។

**សមាជិកក្រុមជាមួយអ្នកភូមិ :**

ព័ត៌មាននេះត្រូវបាននឹងកំពុងបង្ហាញចំពោះមុខអ្នក ដូច្នេះប្រសិនបើមានកំហុសឆ្គង រឺការបង្ហាញមានខ្វះចន្លោះណាមួយ អ្នកអាចកែតំរូវវាបាន។ នេះជាហេតុផលមួយដែលបញ្ជាក់ថា ការចូលរួមរបស់អ្នកពិតជាមានសារៈសំខាន់ណាស់។

**អត្ថាធិប្បាយ**

អ្នកភូមិដែលបានចូលរួមក្នុងសកម្មភាពនេះ បានធ្វើការវិភាគព័ត៌មាន និងកែតម្រូវយ៉ាងយកចិត្តទុកដាក់ប្រសិនបើមានកំហុសឆ្គងណាមួយ។

**សមាជិកក្រុម និងអ្នកភូមិ**

បុរសចាស់ម្នាក់ : ចំនួនប្រជាជនសរុបត្រឹមត្រូវគឺ ៩៥០នាក់

ស្ត្រី : ពួកយើងនិយាយអំពីប្រភេទខុសគ្នានៃជំងឺ ដែលប៉ះពាល់មនុស្សនៅក្នុងភូមិ។

ជំងឺដែលប៉ះពាល់ដល់ប្រជាជនក្នុងភូមិមានដូចជា :

- ជំងឺរាគមួល ដែលច្រើនកើតលើកុមារ
- ជំងឺផ្លូវដង្ហើមដែលកើតឡើងចំពោះមនុស្សចាស់
- ជំងឺគ្រុនចាញ់ ជំងឺគ្រុន
- ជំងឺគ្រុនឈាមដែលកើតឡើងចំពោះកុមារ
- ក្រៅពីជំងឺដែលបានបង្ហាញខាងលើ ប្រជាជនក្នុងភូមិបានបង្ហាញអំពីបញ្ហាដែលធ្លាប់ជួបប្រទះរាល់ឆ្នាំដែលបង្កឡើងដោយឧស្ម័ន? តើហេតុផលនៃបញ្ហានេះបង្កឡើងដោយអ្វី?

បុរសចាស់ម្នាក់ : ប្រជាជនមួយចំនួនហូបអាហារសំបូរជាតិប្រេងដែលមិនអាចរំលាយបានក្នុងរាងកាយរបស់ពួកគេ។ នៅពេលអាហារមានរសជាតិឆ្ងាញ់ ពួកគេហូបកាន់តែច្រើន។ ដូច្នេះ វាបណ្តាលឱ្យមានជំងឺទល់លាមក និងជាតិឧស្ម័នច្រើនក្នុងរាងកាយរបស់ពួកគេ។

សមាជិកក្រុម : តារាងនេះបង្ហាញពីសាលារៀន១ ផ្ទះ **Panchayat Kendra** ដើមឈើ ដីចំការ ដីស្រែផ្សេងៗ។ នេះជាផែនទីភូមិ។ ចំណែកខាងនេះវិញ ជាអណ្តូង និងផ្លូវដែលសំបូរទៅភក់។ ប្រជាជននៅក្នុងភូមិមានបញ្ហាជាច្រើនក្នុងការឆ្លងកាត់ ផ្ទុយទៅវិញប្រសិនបើផ្លូវត្រូវបានកសាងឱ្យបានល្អ វាជាការប្រសើរមែនទែន។

**អត្ថាធិប្បាយ**

កំឡុងពេលអនុវត្តនីតិវិធីសាស្ត្រនេះ បញ្ហាផ្សេងៗដែលប្រមូលបាន ត្រូវបានកំនត់តាមរយៈ ការផ្តល់នូវអាទិភាព២/៣ នៃបញ្ហាសំខាន់។ បន្ទាប់មកបញ្ហានឹងត្រូវបានដោះស្រាយទៅលើការយល់ព្រមគ្នាទៅវិញទៅមកជាមូលដ្ឋាន។

**ប្រតិកម្មជាមួយអ្នកភូមិ :**

ស្ត្រី : តើសុខភាពស្ត្រី រងការប៉ះពាល់ធ្ងន់ធ្ងរបៀបណា? តើប្រពលភាព (ក៏រិតសកម្ម) នៃជំងឺជាអ្វី? តើអ្នកកំនត់ក៏រិតរបស់ជំងឺដោយរបៀបណា? ពីក៏រិត ១ ទៅ ១០ រឺ?

បុរស : ៦

ស្ត្រី : តើមានមនុស្សប៉ុន្មាននាក់ ដែលរងការប៉ះពាល់ដោយជំងឺរបស់ស្ត្រីនេះ? តើស្ត្រីប៉ុន្មាននាក់ដែលរងការប៉ះពាល់ដោយជំងឺនេះ? តើអ្នកកំនត់ក៏រិតក្នុងបទដ្ឋានពី ១ ទៅ ១០ រឺ?

ស្ត្រី : ៥

**គំរោងស្នើសុំពី Pradhan (Village head)**

ក្នុងគោលបំណងគាំទ្រការសាបព្រោះ រឺការដាំដុះ ដំណាំជាមួយជំនួយពី **Gram Panchayat** និងការចូលរួមពីប្រជាជនក្នុងភូមិ គំរោងកាងារមួយត្រូវបានបង្កើតឡើង។ គំរោងស្នើសុំមានដូចជា អណ្តូងស្នប់ត្រូវបានកសាង ដូច្នេះកសិករជាច្រើននឹងទទួលផលពីអណ្តូងនេះ។ គំរោងស្នើសុំនេះ គួរតែត្រូវបានផ្ញើរទៅឱ្យគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធទាំងអស់ ។

**អត្ថាធិប្បាយ**

បន្ទាប់ពីដំណើរការគំរោងស្នើសុំ ការប៉ាន់ប្រមាណមួយត្រូវបានធ្វើឡើងដើម្បីធ្វើឱ្យប្រាកដថា ប្រជាជននៅក៏រិតក្រោមបានទទួល តាមរយៈដំណើរការដូចខាងក្រោម :

១. ក្នុង **Gram Panchayat, Ganeshpur, Zila Sitapur** ប្រលាយទឹក ១១០ម៉ែត្រ និងផ្លូវ **semi-pakka** ត្រូវបានកសាង។

២. នៅក្នុង **Sultanpur gram Panchayat, handpump,** ប្រលាយទឹក ៥០ ម៉ែត្រ និង **semi-pakka road** ត្រូវបានកសាង

៣. នៅក្នុង **Durgapur gram Panchayat,** ការប៉ាន់ប្រមាណក្នុងការបង្កើតកសិដ្ឋានចិញ្ចឹមត្រីត្រូវបានលេចចេញជារូបរាង។

ក្នុងវិធីសាស្ត្រនេះតាមរយៈដំណើរការក្នុងតំបន់នៃ **Uttar Pradesh** ដូចជា **Mau, Gorakhpur, Mirzapar, Devariya, Giazipur, Banda, Jalgon** ការប៉ាន់ប្រមាណទាំងអស់នេះ និងត្រូវបានអនុវត្តតាមរយៈវិធីសាស្ត្រដ៏ជោគជ័យមួយ ។

លទ្ធផលអាចបង្ហាញឱ្យឃើញយ៉ាងយឺតៗ ។ ប្រជាជនក្នុងភូមិនឹងមានសង្ឃឹម ហើយការប៉ាន់ប្រមាណ និងត្រូវបានពង្រឹង ដែលធ្វើឱ្យមានការប្រែប្រួលក្នុងភូមិរបស់ពួកគេ ។

ការរបង្ហាញដោយ លោក **Sahabhagi Sikshan Trust Lucknow**